# ទន្លេសេសាន A1, A2 & A4i



**ខេត្ត** : ស្ទឹងត្រែង និង រតនគិរី

**ស្រុក** : សៀមប៉ាង សេសាន វើនសៃ តាវែង និង អណ្តូងមាស

**ផ្ទៃដី ( ហិកតា)** : ២០.៥០៤

**រយៈកំពស់ ( ម៉ែត្រ)** : ៤៣ ដល់ ១៦៦

**កូអរដោនេចំណុចកណ្ដាល** : ១៣$^{0}$៥០់ជ ១០៧$^{0}$២៣់ក

### ការពិពណ៌នាទីកន្លែង

តំបន់ IBA នេះ រួមមានទន្លេសេសានទាំងអស់លាតសន្ធឹងក្នុងប្រទេសកម្ពុជា និង រុក្ខជាតិប្រព័ន្ធទន្លេ ចាប់ពីកន្លែងប្រសព្វត្រង់ទន្លេសេកុងរហូតដល់ព្រំដែនប្រទេសកម្ពុជា-វៀតណាម ។ ទន្លេសេសានមានប្រវែងទទឹងចាប់ពីប្រហែល១៥០ម៉ែត្រនៅផ្នែកខាងលើរហូតដល់៣០០ម៉ែត្រនៅផ្នែកខាងក្រោម ។ ភាគច្រើនបំផុតរបស់ទន្លេនេះគ្របដណ្តប់ដោយដីខ្សាច់ និង គ្រួសនៅផ្នែកខាងក្រោមបំផុតរបស់ទន្លេត្រង់ចំណុចខាងក្រោមភូមិខ្សាច់ថ្មីសម្បូរដោយផ្ទាំងថ្ម ។ ទន្លេនៅផ្នែកខាងលើសម្បូរទៅដោយគ្រួសរួមជាមួយនឹងព្រៃគុម្ពោតទាបៗ រីឯទន្លេនៅផ្នែកខាងក្រោមសម្បូរទៅដោយដីខ្សាច់ មានព្រៃគុម្ពោតដុះតិចតួច ឬ គ្មានតែម្តង ។ រុក្ខជាតិប្រព័ន្ធទន្លេគ្របដណ្តប់លើសលប់ដោយព្រៃពាក់កណ្តាលស្រោង និង ព្រៃរបោះដែលដុះនៅជាប់បន្ទាប់ពីព្រៃពាក់កណ្តាលស្រោងតាមមាត់ទន្លេ ។ រុក្ខជាតិប្រព័ន្ធទន្លេជាទូទៅមានការថយចុះគ្រប់ទីកន្លែងនៅតាមដងទន្លេ ដោយសារការធ្វើកសិកម្មពនេចរ ។

តំបន់នេះបានទ្រទ្រង់ការនៅសេសសល់ពពួកសត្វស្លាបរកស៊ី ស្នាក់អាស្រ័យ និង ពងកូនតាមប្រព័ន្ធទន្លេបានល្អបំផុត ដែលពីមុនពួកវាមានវត្តមាននៅគ្រប់ទីកន្លែងនៅតាមបណ្តាដងទន្លេដែលមានដីទំនាបៗក្នុងប្រទេសឥណ្ឌូចិន ។ ពពួកសត្វទាំងនោះរួមមានត្រដេវវិចទន្លេ ទន្រ្ទីតទន្លេ ជង្គង់ក្រាស់ចំពុះខ្មៅ និង រំពេទន្លេ ដែលតំបន់នេះបានទ្រទ្រង់លើសពី១%នៃចំនួនសត្វជីវភូមិសាស្ត្រនៅក្នុងតំបន់អាស៊ីដែលពីមុនមាន២% ។ លើសពីនេះទៀត តំបន់នេះបានទ្រទ្រង់ប្រភេទខ្ញុំប៉ដីមេគង្គលើ ដែលបច្ចុប្បន្នប្រភេទនេះគេបានចាត់ទុកថា ជាប្រភេទដែលមាននៅតែក្នុងតំបន់អាងទន្លេមេគង្គផ្នែកខាងលើ និង ដៃសំខាន់ៗរបស់វាប៉ុណ្ណោះ ។ តំបន់នេះ អាចចាត់ទុកជាតំបន់ចុងក្រោយនៅក្នុងប្រទេសឥណ្ឌូចិន ដែលផ្តល់ទីកន្លែងពងកូនសម្រាប់រំពេពោះខ្មៅទោះជាវាមានប្រហែលមួយ ឬ ពីរគូក៏ដោយនាពេលបច្ចុប្បន្ននេះ និង ដោយមានការផ្លាស់ប្តូររបបទឹកហូរដោយសារការអភិវឌ្ឍន៍គំរោងវារីអគ្គិសនីនៅក្នុងទន្លេប៉ែកខាងលើ ប្រភេទនេះនឹងឈានទៅរកការផុតពូជ ។

### ប្រភេទសត្វស្លាបសំខាន់ៗ

| ឈ្មោះខ្មែរ | ឈ្មោះអង់គ្លេស | ឈ្មោះវិទ្យាសាស្ត្រ | លក្ខណៈវិនិច្ឆ័យIBA | |
|---|---|---|---|---|
| ខ្ញុំប៉ដីមេគង្គលើ | Mekong Wagtail | *Motacilla samveasnae* | A1 | A2 |
| ត្មាតផេះ | White-rumped Vulture | *Gyps bengalensis* | A1 | |
| ត្មាតភ្លើង | Red-headed Vulture | *Sarcogyps calvus* | A1 | |
| ត្រដក់តូច | Lesser Adjutant | *Leptoptilos javanicus* | A1 | |

| | | | |
|---|---|---|---|
| ទន្ទ្រីតទន្លេ | Small Pratincole | *Glareola lactea* | A4i |
| រំពេពោះខ្មៅ | Black-bellied Tern | *Sterna acuticauda* | A1 |
| រំពេទន្លេ | River Lapwing | *Vanellus duvaucelii* | A4i |
| អកត្រីក្បាលប្រផេះ | Grey-headed Fish Eagle | *Ichthyophaga ichthyaetus* | A1 |

**ប្រភេទសត្វប្រមូលផ្តុំក្នុងតំបន់មួយជាក់លាក់**

មានសត្វស្លាបមួយប្រភេទរស់នៅក្នុងប្រភេទព្រៃស្រោង និង ពីរប្រភេទរស់នៅក្នុងប្រភេទព្រៃរបោះ (សូមមើលតារាងឧបសម្ព័ន្ធ៤) ។

**ប្រភេទពានរថនិតទទួលរងការគំរាមកំហែងពិភពលោក**

ស្វាក្តាម និង ស្វាព្រាម ។

**ប្រភេទអណ្តើក កន្ធាយ និង ក្រពើទទួលរងគករគំរាមកំហែងពិភពលោក**

ក្រពើទន្លេ (ក្រពើត្រី) និង អណ្តើកសោមញ្ញី ។

**ការគំរាមកំហែងលើជីវៈចំរុះ**

ការគំរាមកំហែងចំបងលើជីវៈចំរុះនៅក្នុងតំបន់ IBA នេះ រួមមានការប្រមាញ់ដែលធ្ងន់ធ្ងរបំផុតនោះគឺការប្រមូលយកពងកូន និង ការរំខានដោយសារសកម្មភាពមនុស្សនៅលើវាលខ្សាច់ ដែលអាចប៉ះពាល់ជាអវិជ្ជមានដល់ការពងកូនរបស់ប្រភេទសត្វស្លាបពងកូនលើវាលខ្សាច់ ។ ការគំរាមកំហែងមួយផ្សេងទៀតនោះ គឺការថយចុះ និង ការបាត់បង់ព្រៃឈើដុះតាមប្រព័ន្ធទន្លេដោយសារការកាប់រំលំ និង ការរានយកដីសម្រាប់ធ្វើកសិកម្ម ។ ការគំរាមកំហែងលើសពីនេះទៀត គឺបណ្តាលមកពីការអភិវឌ្ឍន៍គំរោងវារីអគ្គិសនីដែលមានស្រាប់ និង គ្រោងធ្វើបន្ថែមនៅក្នុងទន្លេផ្នែកខាងលើក្នុងប្រទេសវៀតណាម ។ មានការបង្ហាញយ៉ាងច្បាស់ថា ការប្រែប្រួលរបបទឹកហូរដោយសារទំនប់វារីអគ្គិសនីមានស្រាប់គឺកំពុងប៉ះពាល់យ៉ាងខ្លាំងជាអវិជ្ជមានដល់ពពួកសត្វស្លាបរកស៊ី ស្នាក់អាស្រ័យ និង ពងកូនតាមប្រព័ន្ធទន្លេ ដោយសារមានការលិចលង់យ៉ាងឆាប់រហ័សដែលបានបំផ្លាញបំបុករបស់សត្វ និង មានការប្រែប្រួលដំណើរការនៃកំណកដី ដែលនាំឱ្យមានការថយចុះនូវទីកន្លែងពងកូនរបស់ពួកវា ។

**អនុសាសន៍**

ការប្រឹងប្រែងត្រូវតែធ្វើឡើង ដើម្បីការពារប្រភេទសត្វស្លាបដែលពងកូនលើវាលខ្សាច់ ខណៈដែលពួកវាកំពុងពងកូន ។ កិច្ចព្រមព្រៀងសហគមន៍អាចបង្កើតឡើងតាមភូមិនិមួយៗ ដើម្បីកុំឱ្យតំបន់ទាំងនោះមានការរំខាន ។

ការអភិរក្សទន្លេសេសានគួរតែធ្វើឡើងនៅតាមបណ្តោយប្រព័ន្ធទន្លេទាំងអស់ ដោយផ្តោតលើផ្នែកតូចៗដាច់ៗពីគ្នា ដែលអាចទទួលរងផលវិបាកនាំឱ្យមានភាពមហន្តរាយ ។

ការបង្កើតភូមិថ្មីៗ និង ការអភិវឌ្ឍន៍កសិកម្មតាមដងទន្លេមិនគួរត្រូវបានលើកទឹកចិត្តឡើយ ហើយផ្នែកសំខាន់ៗដែលមានព្រៃឈើប្រព័ន្ធទន្លេ គួរតែការពារឱ្យបានតឹងរឹងពីការកាប់រំលំ និង ការធ្វើកសិកម្មពនេចរ ។

ការសិក្សាស្រាវជ្រាវគួរធ្វើឡើង ដោយផ្តោតលើផលប៉ះពាល់នៃការអភិវឌ្ឍន៍គំរោងទំនប់វារីអគ្គិសនីនៅតាមដងទន្លេសេសានលើពពួកសត្វស្លាប ជាពិសេសប្រភេទដែលពងកូនលើវាលខ្សាច់ ។

**ឯកសារយោង**

Davidson, P., Poole, C. M. and Duckworth J. W. (2001) Mekong Wagtail (*Motacilla samvaesnae*): the great river's only known avian endemic. *Bull. Oriental Bird Club* 34: 56-59.

Davies, J. D. (1994) *Wetland surveys in Cambodia to identify sites of international importance.* Kuala Lumpur: Asian Wetland Bureau.

Duckworth, J. W., Alström, P., Davidson, P., Evans, T. D., Poole, C. M., Tan Setha and Timmins, R. J. (2001) A new species of wagtail from the lower Mekong basin. *Bull. Brit. Ornith. Club* 121(3): 152-182.

Goes, F. (1999) Notes on selected bird species in Cambodia. *Forktail* 15: 25-27.

Mundkur, T., Carr, P., Sun Hean and Chhim Somean (1995) *Surveys for large waterbirds in Cambodia, March-Apri l 1994.* Cambridge, UK: IUCN/SSC.

Poole, C. M. Duckworth, J. W. and van Zalinge, N. J. (in prep.) Bird observations from the Mekong and major tributaries in north-east Cambodia, 1998-2000.

Tan Setha (2002) Mekong Wagtail: a species new to science discovered in northeast Cambodia. *Cambodia Bird News* : 9: 14-17.

Timmins, R. J. and Men Soriyun (1998) *A wildlife survey of the Tonle San and Tonle Srepok river basins in north-east ern Cambodia.* Hanoi and Phnom Penh: Fauna & Flora International and the Wildlife Protection Office.

Thomas, W.W. 1964. *A preliminary list of the birds of Cambodia*. Unpubl.

van Zalinge, N. J., Poole, C. M., Duckworth, J. W. and Goes, F. (2002) Waterbird counts on the Mekong, Sekong, Sesan and Srepok rivers. *Cambodia Bird News* 9: 18-29.